ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ........សហវ.....

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ នៃសាខាពន្ធដារខណ្ឌទាំង ០៧ នៅរាជធានីភ្នំពេញ

លិខិតចូល

ថ្ងៃទី.... ខែ.... ឆ្នាំ20..

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ដូចបានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យលេខ ១៣៨អនក្រ/បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានពន្ធដារ ឱ្យទៅជាអគ្គនាយកដ្ឋានពន្ធដារ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅរាជធានីភ្នំពេញ ត្រូវបានបង្កើតសាខាពន្ធដារខ័ណ្ឌនីមួយៗដូចខាងក្រោម ស្ថិតនៅក្រោមចំណុះផ្ទាល់របស់អគ្គនាយកដ្ឋានពន្ធដារ មានឋានៈស្មើសាខាពន្ធដារខេត្ត-ក្រុង ។ សាខាពន្ធដារខ័ណ្ឌក្នុងរាជធានីភ្នំពេញទាំងនោះ រួមមាន:

- សាខាពន្ធដារខ័ណ្ឌចំការមន
- សាខាពន្ធដារខ័ណ្ឌទួលគោក
- សាខាពន្ធដារខ័ណ្ឌ៧មករា
- សាខាពន្ធដារខ័ណ្ឌដូនពេញ
- សាខាពន្ធដារខ័ណ្ឌឫស្សីកែវ
- សាខាពន្ធដារខ័ណ្ឌមានជ័យ
- សាខាពន្ធដារខ័ណ្ឌដង្កោ

**ប្រការ២.-**

សាខាពន្ធដារខ័ណ្ឌនីមួយៗក្នុងរាជធានីភ្នំពេញ ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអនុប្រធានសាខាពន្ធដារមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ៣.-**

សាខាពន្ធដារខ័ណ្ឌនីមួយៗក្នុងរាជធានីភ្នំពេញ ទទួលខុសត្រូវក្នុងការគ្រប់គ្រងអ្នកជាប់ពន្ធមធ្យមពន្ធតាមរបបពិតដែលជាប្រព័ន្ធស្វ័យប្រកាសពន្ធដោយអ្នកជាប់ពន្ធខ្លួនឯង និងគ្រប់គ្រងអ្នកជាប់ពន្ធក្នុងរបបម៉ៅការ ស្ថិតក្នុងមណ្ឌលដែនដីរបស់ខ្លួន ។ លក្ខណៈសម្បត្តិរបស់អ្នកជាប់ពន្ធមធ្យមពន្ធតាមរបបពិត ដែលជាប្រព័ន្ធស្វ័យប្រកាសពន្ធដោយអ្នកជាប់ពន្ធខ្លួនឯង និងរបបម៉ៅការ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក ។

**ប្រការ៤.-**

សាខាពន្ធដារខ័ណ្ឌនីមួយៗក្នុងរាជធានីភ្នំពេញ មានការិយាល័យចំណុះចំនួន ០៤ គឺ :

- ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី
- ការិយាល័យចាត់ចែងលិខិតប្រកាស
- ការិយាល័យសវនកម្មពន្ធ
- ការិយាល័យបំណុលពន្ធ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ អង្គការលេខរបស់សាខាពន្ធដារខ័ណ្ឌនីមួយៗក្នុងរាជធានីភ្នំពេញ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៥.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យទាំង ៤ នៃសាខាពន្ធដារខ័ណ្ឌនីមួយៗនៅរាជធានីភ្នំពេញ ជាទូទៅដូចគ្នានឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំដែរ និងមានតួនាទីនិងភារកិច្ចបន្ថែមក្នុងការគ្រប់គ្រង និងប្រមូលពន្ធលើអ្នកជាប់ពន្ធក្នុងរបបម៉ៅការ និងប្រភេទពន្ធមួយចំនួនទៀត ។ តួនាទី និងភារកិច្ចបន្ថែម មានជាអាទិ៍:

១- ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី មានតួនាទីនិងភារកិច្ចបន្ថែមគឺ: ប្រមូលពន្ធតែមប្រិ៍យ៍ ពន្ធមធ្យោបាយលើយានយន្តគ្រប់ប្រភេទ ពន្ធឈ្នួលផ្ទះ-ដី

២- ការិយាល័យចាត់ចែងលិខិតប្រកាស មានតួនាទី និងភារកិច្ចបន្ថែមគឺ: ធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធក្នុងរបបម៉ៅការ

៣- ការិយាល័យសវនកម្មពន្ធ មានតួនាទី និងភារកិច្ចបន្ថែមគឺ: អាចធ្វើសវនកម្មលើអ្នកជាប់ពន្ធក្នុងរបបម៉ៅការក្នុងករណីចាំបាច់

៤- ការិយាល័យបំណុលពន្ធ មានតួនាទី និងភារកិច្ចបន្ថែមគឺ: ប្រមូលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធ និងបង់ប្រាក់ពន្ធទៅរតនាគារ ឬធនាគារ ចុះបញ្ជីការគណនេយ្យ និងគ្រប់គ្រងស្ថិតិគ្រប់ប្រភេទពន្ធ ។

**ប្រការ៦.-**

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬអង្គភាពជំនាញដទៃ សាខាពន្ធដារខ័ណ្ឌនីមួយៗក្នុងរាជធានីភ្នំពេញ ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធទាំងនោះ សុំគោលការណ៍ពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន ដើម្បីរួមគ្នាដោះស្រាយ ។

**ប្រការ៧.-**

ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណា ដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៨.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៨

**គាត ឈន់**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ" ដើម្បីជូនជ្រាប "
- ដូចប្រការ ៨
- កាលប្បវត្តិ-ឯកសារ